នស/រកត/០៥២៦/៥៩៣

# ព្រះរាជក្រឹត្យ
# ស្ដីពី
# លក្ខន្តិកៈនៃអត្តគ្រូបង្រៀន

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦ ន.ស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអប់រំ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្ដម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០១/៣៤១ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតបឋម

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ព្រះរាជក្រឹត្យនេះ កំណត់អំពីលក្ខន្តិកៈនៃអង្គគ្រូបង្រៀន ដើម្បីប្រមូលផ្តុំនិងគ្រប់គ្រងបុគ្គលិកអប់រំដែលទទួលការអប់រំ ការបណ្តុះបណ្តាលគរុកោសល្យ ឬវគ្គតម្រង់ទិស មានបទពិសោធការងារ មានចំណេះដឹង និងកំពុងបំពេញការងារក្នុងវិស័យអប់រំ។

**មាត្រា២ .-**

ព្រះរាជក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះបុគ្គលិកអប់រំ ដែលបម្រើការងារក្នុងវិស័យអប់រំនៅតាមគ្រឹះស្ថានសិក្សានិងអង្គភាពនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី២

## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៣ .-**

ក្រសួងអប់រំ យុវជន និងកីឡា មានសមត្ថកិច្ចគ្រប់គ្រងអង្គគ្រូបង្រៀន ដើម្បីធានានូវសង្គតិភាពនិងគុណភាពនៃបុគ្គលិកអប់រំនៃអង្គគ្រូបង្រៀន។

ក្រសួងអប់រំ យុវជន និងកីឡា មានសមត្ថកិច្ចពិនិត្យនិងធានានូវនីត្យានុកូលភាព និងត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

- ណែនាំដល់អង្គភាពក្រោមឱវាទផ្ទាល់របស់ក្រសួងនិងរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់កម្រិត ឱ្យអនុវត្តមុខងារនិងភារកិច្ចដោយអនុលោមតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ ក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងនិងចាត់ចែងបុគ្គលិកអប់រំនៃអង្គគ្រូបង្រៀនដែលត្រូវបានផ្ទេរឬដាក់ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់អង្គភាពនិងរដ្ឋបាលថ្នាក់ក្រោមជាតិសាមី
- បង្គាប់ដល់អង្គភាពក្រោមឱវាទផ្ទាល់របស់ក្រសួងនិងរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់កម្រិត ឱ្យកែប្រែ ឬលុបសេចក្តីសម្រេចរបស់ខ្លួនដែលផ្ទុយនឹងបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ
- ចេញសេចក្តីសម្រេចព្យួរឬលុបសេចក្តីសម្រេចរបស់អង្គភាពក្រោមឱវាទផ្ទាល់របស់ក្រសួងដែលផ្ទុយនឹងបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ
- ស្នើក្រសួងមហាផ្ទៃចាត់វិធានការកែតម្រូវ ឬព្យួរ ឬក៏លុបសេចក្តីសម្រេចឬដីការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលផ្ទុយនឹងបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ
- លើកសំណើជូនរាជរដ្ឋាភិបាល ដើម្បីមានវិធានការធានានីត្យានុកូលភាព ក្នុងករណីដែលសេចក្តីសម្រេចរបស់ក្រសួង ស្ថាប័ននានា ផ្ទុយនឹងបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា៤ .-**

ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងមុខងារសាធារណៈ ត្រូវសហការរៀបចំលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធដែលតម្រូវដោយព្រះរាជក្រឹត្យនេះ ព្រមទាំងកំណត់សេចក្ដីណែនាំ បែបបទ និងនីតិវិធីចាំបាច់ដើម្បីធានា ការអនុវត្តព្រះរាជក្រឹត្យឱ្យមានប្រសិទ្ធភាព។

## ជំពូកទី៣
## មុខតំណែងក្នុងអង្គគ្រូបង្រៀន

**មាត្រា៥ .-**

មុខតំណែងក្នុងអង្គគ្រូបង្រៀន មានមុខតំណែងវិជ្ជាជីវៈនិងមុខតំណែងគ្រប់គ្រងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង។

មុខតំណែងវិជ្ជាជីវៈនិងមុខតំណែងគ្រប់គ្រង ត្រូវមានការពិពណ៌នាអំពីមុខតំណែងនិងការបញ្ជាក់អំពី គុណវុឌ្ឍិសម្រាប់មុខតំណែងនីមួយៗឱ្យបានច្បាស់លាស់។

មុខតំណែងក្នុងអង្គគ្រូបង្រៀន ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីបានពិគ្រោះយោបល់ ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

មុខតំណែងគ្រប់គ្រងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

## ជំពូកទី៤
## ការជ្រើសរើស

**មាត្រា៦ .-**

ការជ្រើសរើសចូលក្នុងអង្គគ្រូបង្រៀន មានពីររបៀបគឺៈ

១-ការជ្រើសរើសបណ្ដុះបណ្ដាលចូលក្នុងអង្គគ្រូបង្រៀន។

២-ការជ្រើសរើសបញ្ចូលក្នុងអង្គគ្រូបង្រៀន។

ចំនួនមុខតំណែងក្នុងការជ្រើសរើស ត្រូវអនុវត្តផ្អែកលើផែនការនិងគម្រោងថវិកាប្រចាំឆ្នាំនីមួយៗ ដែលសម្រេចដោយរាជរដ្ឋាភិបាល។

**មាត្រា៧ .-**

ការជ្រើសរើសបណ្ដុះបណ្ដាលចូលក្នុងអង្គគ្រូបង្រៀន ត្រូវធ្វើឡើងតាមរយៈការប្រឡងប្រជែងពីក្នុង ចំណោមបេក្ខជន ដែលមានគុណវុឌ្ឍិសមស្របទៅនឹងមុខតំណែង ដើម្បីធ្វើការអប់រំបណ្ដុះបណ្ដាលជំនាញ គរុកោសល្យនិងតម្រង់ទិសវិជ្ជាជីវៈគ្រូបង្រៀន។

ការជ្រើសរើសបញ្ចូលក្នុងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្ដម ដែលបម្រើការងារនៅគ្រឹះស្ថានឧត្ដមសិក្សា បេក្ខជនត្រូវមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ឬសមមូលឡើងទៅ ហើយត្រូវឆ្លងកាត់វគ្គតម្រង់ទិសវិជ្ជាជីវៈ ដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៨ .-**

ការជ្រើសរើសបញ្ចូលក្នុងអង្គគ្រូបង្រៀន ត្រូវធ្វើឡើងតាមរយៈការប្រឡងប្រជែងពីក្នុងចំណោម បេក្ខជនដែលមានវិញ្ញាបនបត្រគរុសម្បទាវិជ្ជាជីវៈឬវគ្គតម្រង់ទិសវិជ្ជាជីវៈ និងមានគុណវុឌ្ឍិសមស្របទៅនឹង មុខតំណែង។

**មាត្រា៩ .-**

បែបបទ នីតិវិធី និងយន្តការនៃការប្រឡងប្រជែងជ្រើសរើសចូលក្នុងអង្គគ្រូបង្រៀន ត្រូវអនុវត្តដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា១០ .-**

បេក្ខជនដែលអាចចូលរួមប្រឡងប្រជែងជ្រើសរើសចូលក្នុងអង្គគ្រូបង្រៀន ដោយអនុលោមតាមមាត្រា៧ និងមាត្រា៨ នៃព្រះរាជក្រឹត្យនេះ ត្រូវបំពេញលក្ខណវិនិច្ឆ័យមូលដ្ឋានដូចខាងក្រោម៖

- សញ្ជាតិខ្មែរ
- លក្ខខណ្ឌអាយុ ផ្អែកលើការកំណត់ដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន
- សញ្ញាបត្របរិញ្ញាបត្រ ឬសមមូល ឬក៏សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិបូក៤(បួន)ឆ្នាំ នៃការបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានគរុកោសល្យនៃក្រសួងអប់រំ យុវជន និងកីឡា ឡើងទៅ
- មិនប្រាសចាកសិទ្ធិខាងផ្លូវរដ្ឋប្បវេណី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ
- មិនដែលមានទោសឧក្រិដ្ឋឬមជ្ឈិមពីរឿងល្មើសប៉ះពាល់ដល់ទំនៀមទម្លាប់ កិត្តិយស និងភាពសុចរិត។

លក្ខណវិនិច្ឆ័យលម្អិតនិងគុណវុឌ្ឍិផ្សេងទៀតសម្រាប់មុខតំណែងនីមួយៗ អាចកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា និង/ឬក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៥
## ការបណ្តុះបណ្តាលគរុកោសល្យនិងការបណ្តុះបណ្តាលតម្រង់ទិស

**មាត្រា១១ .-**

បុគ្គលិកអប់រំស្ថិតក្រោមលក្ខន្តិកៈនៃអង្គគ្រូបង្រៀន ដែលត្រូវបំពេញមុខងារផ្នែកបង្រៀនឬស្រាវជ្រាវនៅមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា ត្រូវឆ្លងកាត់ការបណ្តុះបណ្តាលគរុកោសល្យ ដើម្បីទទួលបានវិញ្ញាបនបត្រគរុសម្បទាវិជ្ជាជីវៈ។

បុគ្គលិកអប់រំស្ថិតក្រោមលក្ខន្តិកៈនៃអង្គគ្រូបង្រៀន ដែលត្រូវបំពេញមុខងារផ្នែកបង្រៀនឬស្រាវជ្រាវនៅឧត្តមសិក្សា ត្រូវឆ្លងកាត់វគ្គតម្រង់ទិសវិជ្ជាជីវៈ។

គ្រឹះស្ថានគរុកោសល្យនៃក្រសួងអប់រំ យុវជន និងកីឡា ជាគ្រឹះស្ថានដែលមានសមត្ថកិច្ចក្នុងការផ្តល់ការបណ្តុះបណ្តាលគរុកោសល្យ។

ការកំណត់ការបណ្តុះបណ្តាលគរុកោសល្យ ការផ្តល់វិញ្ញាបនបត្រគរុសម្បទាវិជ្ជាជីវៈ និងសុពលភាពវិញ្ញាបនបត្រគរុសម្បទាវិជ្ជាជីវៈ ព្រមទាំងវគ្គតម្រង់ទិសវិជ្ជាជីវៈ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

## ជំពូកទី៦
## បុគ្គលិកអប់រំក្នុងក្របខ័ណ្ឌមន្ត្រីរាជការ
### ផ្នែកទី១
### ក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់

**មាត្រា១២ .-**

បុគ្គលិកអប់រំក្នុងក្របខ័ណ្ឌមន្ត្រីរាជការនៃអង្គគ្រូបង្រៀន ត្រូវបានរៀបចំឱ្យស្ថិតក្នុងក្របខ័ណ្ឌប្រភេទ ក ដែលមាន៣(បី)កម្រិត ដូចខាងក្រោម៖

- ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន
- ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតបឋម។

**មាត្រា១៣ .-**

ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម ប្រមូលផ្តុំនិងគ្រប់គ្រងបុគ្គលិកអប់រំជាមន្ត្រីរាជការ ដែលមានសញ្ញាបត្រជំនាញនិងបានទទួលការបណ្តុះបណ្តាលគរុកោសល្យឬវគ្គតម្រង់ទិសវិជ្ជាជីវៈ ចាប់ពីកម្រិតបរិញ្ញាបត្រឬសមមូលឡើងទៅ។

មន្ត្រីរាជការនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម មានមុខងារជាអ្នកបង្រៀន អ្នកស្រាវជ្រាវ និង/ឬជាអ្នកគ្រប់គ្រងនៅកម្រិតអប់រំឧត្តមសិក្សានិងមធ្យមសិក្សាទុតិយភូមិឬបំពេញការងារនៅតាមអង្គភាពនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា១៤ .-**

ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម មាន៣(បី)ឋានន្តរសក្តិ៖

- ឋានន្តរសក្តិទី១ ជាឋានន្តរសក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស មាន៦(ប្រាំមួយ)ថ្នាក់
- ឋានន្តរសក្តិទី២ ជាឋានន្តរសក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ មាន៤(បួន)ថ្នាក់
- ឋានន្តរសក្តិទី៣ ជាឋានន្តរសក្តិគ្រូបង្រៀនកម្រិតឧត្តម មាន៤(បួន)ថ្នាក់។

**មាត្រា១៥ .-**

ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន ប្រមូលផ្តុំនិងគ្រប់គ្រងបុគ្គលិកអប់រំជាមន្ត្រីរាជការ ដែលមានសញ្ញាបត្រជំនាញអប់រំនិងបានទទួលការបណ្តុះបណ្តាលគរុកោសល្យ ចាប់ពីកម្រិតបរិញ្ញាបត្រឬសមមូលឡើងទៅ។

មន្ត្រីរាជការនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន មានមុខងារជាអ្នកបង្រៀន អ្នកស្រាវជ្រាវ និង/ឬជាអ្នកគ្រប់គ្រងនៅកម្រិតអប់រំមធ្យមសិក្សាបឋមភូមិឬបំពេញការងារនៅតាមអង្គភាពនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា១៦ .-**

ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន មាន៣(បី)ឋានន្តរសក្តិ៖

- ឋានន្តរសក្តិទី១ ជាឋានន្តរសក្តិគ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែពិសេស មាន៦(ប្រាំមួយ)ថ្នាក់
- ឋានន្តរសក្តិទី២ ជាឋានន្តរសក្តិគ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែ មាន៤(បួន)ថ្នាក់
- ឋានន្តរសក្តិទី៣ ជាឋានន្តរសក្តិគ្រូបង្រៀនកម្រិតមូលដ្ឋាន មាន៤(បួន)ថ្នាក់។

**មាត្រា១៧ .-**

ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតបឋម ប្រមូលផ្តុំនិងគ្រប់គ្រងបុគ្គលិកអប់រំជាមន្ត្រីរាជការ ដែលមានសញ្ញាបត្រជំនាញអប់រំនិងបានទទួលការបណ្តុះបណ្តាលគរុកោសល្យ ចាប់ពីកម្រិតបរិញ្ញាបត្រឬសមមូលឡើងទៅ។

មន្ត្រីរាជការនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតបឋម មានមុខងារជាអ្នកបង្រៀន អ្នកស្រាវជ្រាវ និង/ឬជាអ្នកគ្រប់គ្រងនៅកម្រិតអប់រំបឋមសិក្សា មត្តេយ្យសិក្សា ឬបំពេញការងារនៅតាមអង្គភាពនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា១៨ .-**

ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតបឋម មាន៣(បី)ឋានន្តរសក្តិ៖

- ឋានន្តរសក្តិទី១ ជាឋានន្តរសក្តិគ្រូបង្រៀនកម្រិតបឋមដើមខ្សែពិសេស មាន៦(ប្រាំមួយ)ថ្នាក់
- ឋានន្តរសក្តិទី២ ជាឋានន្តរសក្តិគ្រូបង្រៀនកម្រិតបឋមដើមខ្សែ មាន៤(បួន)ថ្នាក់
- ឋានន្តរសក្តិទី៣ ជាឋានន្តរសក្តិគ្រូបង្រៀនកម្រិតបឋម មាន៤(បួន)ថ្នាក់។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

# ផ្នែកទី២
# ការបណ្តុះបណ្តាលដំបូង កម្មសិក្សា និងការតាំងស៊ប់

**មាត្រា១៩ .-**

ការបណ្តុះបណ្តាលមានពីរប្រភេទ រួមមានការបណ្តុះបណ្តាលដំបូងមុនពេលបម្រើការងារនិងការបណ្តុះបណ្តាលបន្តក្នុងពេលកំពុងបម្រើការងារ។

ក្នុងអំឡុងពេលទទួលការបណ្តុះបណ្តាលដំបូង នៅតាមសាលាគរុកោសល្យ៖

- បេក្ខជនដែលត្រូវបានជ្រើសរើសចូលក្នុងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម មានឋានៈជាគរុនិស្សិតកម្រិតឧត្តម
- បេក្ខជនដែលត្រូវបានជ្រើសរើសចូលក្នុងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន មានឋានៈជាគរុនិស្សិតកម្រិតមូលដ្ឋាន
- បេក្ខជនដែលត្រូវបានជ្រើសរើស ចូលក្នុងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតបឋម មានឋានៈជាគរុនិស្សិតកម្រិតបឋម។

រយៈពេលនៃការបណ្តុះបណ្តាលដំបូងនិងការបណ្តុះបណ្តាលបន្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា២០ .-**

បន្ទាប់ពីការបណ្តុះបណ្តាលដំបូងដោយជោគជ័យ គរុនិស្សិតកម្រិតឧត្តម គរុនិស្សិតកម្រិតមូលដ្ឋាន និងគរុនិស្សិតកម្រិតបឋម ត្រូវបំពេញកម្មសិក្សានៅតាមអង្គភាព ឬគ្រឹះស្ថានសិក្សាសាធារណៈនៅថ្នាក់ជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលសាមីខ្លួនបានជ្រើសរើសនៅពេលប្រឡង។ ការចាត់ឱ្យទៅបំពេញកម្មសិក្សា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

គរុនិស្សិតដែលធ្លាប់បម្រើការងារជាគ្រូបង្រៀន មិនតម្រូវឱ្យធ្វើកម្មសិក្សាឡើយ។

**មាត្រា២១ .-**

រយៈពេលនៃការបណ្តុះបណ្តាលដំបូង ត្រូវរាប់បញ្ចូលជាផ្នែកនៃការធ្វើកម្មសិក្សា។ រយៈពេលនៃកម្មសិក្សាត្រូវបានកំណត់ដូចខាងក្រោម៖

១-គរុនិស្សិតដែលទទួលការបណ្តុះបណ្តាលដំបូងរយៈពេលចាប់ពី១(មួយ)ឆ្នាំ ដល់ក្រោម២(ពីរ)ឆ្នាំ ត្រូវធ្វើកម្មសិក្សារយៈពេល៦(ប្រាំមួយ)ខែ។

២-គរុនិស្សិតដែលទទួលការបណ្តុះបណ្តាលដំបូងរយៈពេលលើសពី២(ពីរ)ឆ្នាំឡើងទៅ ត្រូវធ្វើកម្មសិក្សារយៈពេល៣(បី)ខែ។

**មាត្រា២២ .-**

គរុនិស្សិតគ្រប់ប្រភេទដែលត្រូវចាត់តាំងឱ្យទៅបំពេញកម្មសិក្សា ត្រូវទទួលបៀវត្សតាមឋានន្តរសក្តិថ្នាក់ដើមនៃក្របខ័ណ្ឌ ឬទទួលបានសន្ទស្សន៍បៀវត្សខ្ពស់លើបន្ទាប់នៃសន្ទស្សន៍ចាស់របស់សាមីខ្លួនចំពោះគរុនិស្សិតដែលជ្រើសរើសចេញពីមន្ត្រីរាជការ។

**មាត្រា២៣ .-**

ក្រោយពេលបញ្ចប់កម្មសិក្សាទទួលបានជោគជ័យ គរុនិស្សិតត្រូវបានតាំងស៊ប់តាមក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់ ដូចខាងក្រោម៖

១- គរុនិស្សិតកម្រិតឧត្តម ដែលមាន៖
- សញ្ញាបត្រចាប់ពីថ្នាក់បណ្ឌិតឡើងទៅ ត្រូវតាំងស៊ប់ក្នុងឋានន្តរសក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ២(ក.២.២)
- សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ត្រូវតាំងស៊ប់ក្នុងឋានន្តរសក្តិគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ២ (ក.៣.២)
- សញ្ញាបត្របរិញ្ញាបត្រ ត្រូវតាំងស៊ប់ក្នុងឋានន្តរសក្តិគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ៣(ក.៣.៣)។

២- គរុនិស្សិតកម្រិតមូលដ្ឋាន ដែលមាន៖
- សញ្ញាបត្រចាប់ពីថ្នាក់បណ្ឌិតឡើងទៅ ត្រូវតាំងស៊ប់ក្នុងឋានន្តរសក្តិគ្រូបង្រៀនកម្រិតមូលដ្ឋាន ដើមខ្សែ ថ្នាក់លេខ២(ក.២.២)
- សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ត្រូវតាំងស៊ប់ក្នុងឋានន្តរសក្តិគ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ២ (ក.៣.២)
- សញ្ញាបត្របរិញ្ញាបត្រ ត្រូវតាំងស៊ប់ក្នុងឋានន្តរសក្តិគ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ៣ (ក.៣.៣)។

៣- គរុនិស្សិតកម្រិតបឋម ដែលមាន៖
- សញ្ញាបត្រចាប់ពីថ្នាក់បណ្ឌិតឡើងទៅ ត្រូវតាំងស៊ប់ក្នុងឋានន្តរសក្តិគ្រូបង្រៀនកម្រិតបឋមដើមខ្សែ ថ្នាក់លេខ២(ក.២.២)
- សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ត្រូវតាំងស៊ប់ក្នុងឋានន្តរសក្តិគ្រូបង្រៀនកម្រិតបឋម ថ្នាក់លេខ២ (ក.៣.២)
- សញ្ញាបត្របរិញ្ញាបត្រ ត្រូវតាំងស៊ប់ក្នុងឋានន្តរសក្តិគ្រូបង្រៀនកម្រិតបឋម ថ្នាក់លេខ៣(ក.៣.៣)។

៤- គរុនិស្សិតគ្រប់កម្រិតដែលជ្រើសរើសចេញពីមន្ត្រីរាជការ ត្រូវតាំងស៊ប់ក្នុងឋានន្តរសក្តិសមស្រប នៃក្របខ័ណ្ឌដែលបានប្រឡងជាប់ ដោយទទួលបានសន្ទស្សន៍ខ្ពស់លើបន្ទាប់នៃសន្ទស្សន៍ចាស់ របស់សាមីខ្លួន ព្រមទាំងរក្សាអតីតភាពដែលមានពីមុន។

**មាត្រា២៤ .-**

ការតាំងស៊ប់ក្នុងក្របខ័ណ្ឌនៃអង្គគ្រូបង្រៀននៅថ្នាក់ជាតិ ត្រូវមានការចូលរួមយោបល់ពីគណៈកម្មការ ត្រួតពិនិត្យនិងវាយតម្លៃកម្មសិក្សា ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងឬប្រធានស្ថាប័នឬតំណាង | ប្រធាន |
| - ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់ឬតំណាង | សមាជិក |
| - ប្រធាននាយកដ្ឋានធនធានមនុស្សឬតំណាង | សមាជិក |
| - មន្ត្រីរាជការមួយរូបដែលមានក្របខ័ណ្ឌជាមួយគ្នា | សមាជិក។ |

ដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃកម្មសិក្សា គណៈកម្មការត្រួតពិនិត្យនិងវាយតម្លៃកម្មសិក្សា [illegible] ត្រូវធ្វើកំណត់ហេតុនិងលើកសំណើមករដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពិនិត្យនិង អនុម័តការតាំងស៊ប់ក្នុងក្របខ័ណ្ឌដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា២៥ .-**

ការតាំងស៊ប់ក្នុងក្របខ័ណ្ឌនៃអង្គគ្រូបង្រៀននៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានការចូលរួមយោបល់ពីគណៈកម្មការត្រួតពិនិត្យនិងវាយតម្លៃកម្មសិក្សា ដែលមានសមាសភាពដូចខាងក្រោម៖

- អភិបាលនៃគណៈអភិបាលសាមីឬតំណាង ប្រធាន
- ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់ឬតំណាង សមាជិក
- ប្រធានអង្គភាពទទួលបន្ទុកធនធានមនុស្សឬតំណាង សមាជិក
- អ្នករាជការមួយរូបដែលមានក្របខ័ណ្ឌជាមួយគ្នា សមាជិក។

ដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃកម្មសិក្សា គណៈកម្មការត្រួតពិនិត្យនិងវាយតម្លៃកម្មសិក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើកំណត់ហេតុនិងលើកសំណើមករដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពិនិត្យនិងសម្រេចការតាំងស៊ប់ក្នុងក្របខ័ណ្ឌដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា២៦ .-**

ក្នុងរយៈពេល៣(បី)ខែ យ៉ាងយូរក្រោយផុតកំណត់រយៈពេលកម្មសិក្សា រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដោយផ្អែកលើការវាយតម្លៃរបស់គណៈកម្មការត្រួតពិនិត្យនិងវាយតម្លៃកម្មសិក្សា ត្រូវសម្រេចអំពី៖

- ការតាំងស៊ប់ក្នុងក្របខ័ណ្ឌ ឬ
- ការអនុញ្ញាតឱ្យបន្តកម្មសិក្សា ឬ
- ការបញ្ឈប់មិនឱ្យធ្វើការ។

ក្នុងករណីពុំមានលិខិតបទដ្ឋានគតិយុត្តណាមួយពាក់ព័ន្ធនឹងការតាំងស៊ប់ក្នុងក្របខ័ណ្ឌ ឬការអនុញ្ញាតឱ្យបន្តកម្មសិក្សា ឬក៏ការបញ្ឈប់មិនឱ្យធ្វើការ បន្ទាប់ពីរយៈពេល៣(បី)ខែ ក្រោយផុតកំណត់រយៈពេលកម្មសិក្សា សាមីខ្លួនមានសិទ្ធិទទួលបាននូវការតាំងស៊ប់ ដោយរាប់គិតចាប់ពីថ្ងៃផុតកំណត់នៃកម្មសិក្សា។

គរុនិស្សិតគ្រប់ប្រភេទដែលពុំទទួលបានជោគជ័យក្នុងការធ្វើកម្មសិក្សា ឬពុំទទួលការអនុញ្ញាតឱ្យបន្តកម្មសិក្សា ត្រូវបញ្ឈប់ពីការងារឬត្រូវលុបឈ្មោះចេញពីក្របខ័ណ្ឌចំពោះករណីគរុនិស្សិតដែលត្រូវបានជ្រើសរើសចេញពីមន្ត្រីរាជការ។

## ផ្នែកទី៣
## ការតែងតាំងនិងការបញ្ចប់មុខតំណែង

**មាត្រា២៧ .-**

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌរួច គ្រូបង្រៀនកម្រិតឧត្តម គ្រូបង្រៀនកម្រិតមូលដ្ឋាន និងគ្រូបង្រៀនកម្រិតបឋម អាចទទួលបានការតែងតាំងក្នុងមុខតំណែងគ្រប់គ្រងទំនេរណាមួយក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៅតាមអង្គភាពថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ការតែងតាំងក្នុងមុខតំណែងគ្រប់គ្រងណាមួយក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៅថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្អែកលើគុណវុឌ្ឍិដែលមានកំណត់នៅក្នុងការពិពណ៌នាមុខតំណែង ដោយអនុលោមតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

ការតែងតាំងមុខតំណែងមន្ត្រីរាជការនៃអង្គគ្រូបង្រៀន ត្រូវសម្រេចដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ឬដីកា ផ្អែកលើកម្រិតនៃមុខតំណែងនីមួយៗ ដោយអនុលោមតាមបែបបទនិងនីតិវិធីដែលមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា២៨ ..**

មន្ត្រីរាជការនៃអង្គគ្រូបង្រៀន ត្រូវបានបញ្ចប់មុខតំណែង ក្នុងករណីដូចខាងក្រោម៖

- មរណភាព
- ការចូលនិវត្តន៍ឬការដាក់ឱ្យចូលនិវត្តន៍មុនអាយុកំណត់
- ការលាឈប់ពីមុខតំណែង
- ការបាត់បង់សម្បទាវិជ្ជាជីវៈ
- ការដាក់ឱ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម
- ការបញ្ឈប់ពីការងារដោយបង្ខំឬការបណ្ដេញចេញពីមុខតំណែងមន្ត្រីរាជការ
- ការដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស
- ការផ្លាស់ប្ដូរអង្គវិជ្ជាជីវៈ
- ការផ្ដន្ទាទោសជាបទឧក្រិដ្ឋឬជាបទមជ្ឈិមដោយឥតព្យួរទោស គិតពីសាលក្រមឬសាលដីកាចូលជាស្ថាពរ
- ការលុបនិងការកែសម្រួលរចនាសម្ព័ន្ធនិងមុខតំណែង
- ការសម្រេចផ្សេងទៀតដែលកំណត់ដោយរាជរដ្ឋាភិបាល។

**មាត្រា២៩ ..**

ការបញ្ចប់មុខតំណែងមន្ត្រីរាជការនៃអង្គគ្រូបង្រៀនដែលមានចែងក្នុងមាត្រា២៨ នៃព្រះរាជក្រឹត្យនេះ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ឬដីកា ផ្អែកលើកម្រិតនៃមុខតំណែងនីមួយៗ ដោយអនុលោមតាមបែបបទនិងនីតិវិធីដែលមានចែងក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ដោយហេតុការណ៍មន្ត្រីរាជការនៃអង្គគ្រូបង្រៀនប្រព្រឹត្តកំហុសធ្ងន់ក្នុងវិជ្ជាជីវៈអប់រំ និងផ្អែកលើស្ថានភាពបន្ទាន់ឬករណីចាំបាច់ដើម្បីធានានូវផលប្រយោជន៍សាធារណៈ ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់អាចសម្រេចផ្អាកមុខងារមន្ត្រីរាជការនោះ ហើយត្រូវរៀបចំចាត់ចែងបំពេញតាមបែបបទនិងនីតិវិធីបញ្ចប់មុខតំណែងយ៉ាងយូរ៣០(សាមសិប)ថ្ងៃ ក្រោយការចេញសេចក្ដីសម្រេចផ្អាកមុខងារ។

**មាត្រា៣០ ..**

មន្ត្រីរាជការនៃអង្គគ្រូបង្រៀនដែលត្រូវបានបញ្ចប់មុខតំណែងគ្រប់គ្រងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង ដោយភាពចាំបាច់នៃដំណើរការការងាររបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ឬការលុប និងការកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងគ្រប់គ្រងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង ត្រូវបានរក្សាទុកនូវក្របខ័ណ្ឌ ឋានន្តរសក្តិ ថ្នាក់ ព្រមទាំងអត្ថប្រយោជន៍នៃមុខតំណែងដើមដែលអនុញ្ញាតដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន រហូតដល់មានការតែងតាំងក្នុងមុខតំណែងថ្មីសមស្រប លើកលែងមន្ត្រីរាជការរូបនោះត្រូវបានបញ្ចប់មុខតំណែងដោយមូលហេតុកំហុសធ្ងន់ក្នុងវិជ្ជាជីវៈ ដែលត្រូវអនុវត្តតាមនីតិវិធីដាក់ទណ្ឌកម្មខាងវិន័យឬមូលហេតុផ្សេងទៀតដែលមានចែងក្នុងមាត្រា២៨ នៃព្រះរាជក្រឹត្យនេះ។

**មាត្រា៣១ ..**

មន្ត្រីរាជការនៃអង្គគ្រូបង្រៀនដែលត្រូវបានបញ្ចប់ ឬបាត់បង់មុខតំណែងវិជ្ជាជីវៈ ឬមុខតំណែងគ្រប់គ្រងនៅក្នុងមូលហេតុណាក៏ដោយ មិនមានភារកិច្ចឬសិទ្ធិអំណាចក្នុងមុខតំណែងនោះចាប់ពីកាលបរិច្ឆេទនៃការបាត់បង់មុខតំណែង។

[illegible]មានកាតព្វកិច្ចផ្ទេរនូវទ្រព្យសម្បត្តិរដ្ឋនិងឯកសារផ្លូវការទាំងអស់ដែលបានប្រើប្រាស់ គ្រប់គ្រងនិង[illegible]ក្នុងពេលបំពេញការងារ មកអង្គភាពសាមីវិញឱ្យបានរួចរាល់យ៉ាងយូរ១(មួយ)សប្ដាហ៍ ក្រោយការបញ្ចប់ឬបាត់បង់មុខតំណែង។

**មាត្រា៣២ .-**

មន្ត្រីរាជការនៃអង្គគ្រូបង្រៀន មិនអាចត្រូវតែងតាំង ឬប្រគល់ភារកិច្ចឱ្យបំពេញមុខតំណែងវិជ្ជាជីវៈឬមុខតំណែងគ្រប់គ្រងក្រៅពីអង្គគ្រូបង្រៀន ឬក៏ជ្រើសរើសទៅបំពេញការងារបន្ថែមផ្សេងទៀតក្រៅសេវាអប់រំបានឡើយ លើកលែងតែមានការសម្រេចដោយឡែករបស់រាជរដ្ឋាភិបាល។

## ផ្នែកទី៤
## ការផ្លាស់ប្តូរកន្លែងធ្វើការ

**មាត្រា៣៣ .-**

មន្ត្រីរាជការនៃអង្គគ្រូបង្រៀនត្រូវបំពេញការងារនៅតាមអង្គភាពដែលសាមីខ្លួនបានជ្រើសរើសនៅពេលប្រឡងប្រជែង។

ការផ្លាស់ប្តូរកន្លែងធ្វើការអាចត្រូវបានអនុញ្ញាតដោយផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

- មុខតំណែងទំនេរ
- គុណវុឌ្ឍិសមស្របរបស់មន្ត្រីសម្រាប់មុខតំណែងទំនេរ
- តម្រូវការចាំបាច់នៃការបំពេញមុខតំណែងទំនេររបស់អង្គភាព
- ការឯកភាពពីប្រធានអង្គភាពគ្រប់គ្រងផ្ទាល់ដែលមានតម្រូវការមន្ត្រីបន្ថែម
- ការឯកភាពពីប្រធានអង្គភាពគ្រប់គ្រងផ្ទាល់របស់មន្ត្រីសាមី
- បំពេញបែបបទនិងនីតិវិធីជាធរមាន។

បែបបទនិងនីតិវិធីនៃការផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រីរាជការនៃអង្គគ្រូបង្រៀននៅថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ផ្នែកទី៥
## ការផ្លាស់ប្តូរប្រភេទក្របខ័ណ្ឌក្នុងអង្គគ្រូបង្រៀន

**មាត្រា៣៤ .-**

មន្ត្រីរាជការនៃអង្គគ្រូបង្រៀនត្រូវបំពេញការងារនៅក្នុងប្រភេទក្របខ័ណ្ឌនៃអង្គគ្រូបង្រៀនដែលសាមីខ្លួនបានជ្រើសរើសនៅពេលប្រឡងប្រជែង។

ការផ្លាស់ប្តូរប្រភេទក្របខ័ណ្ឌអាចត្រូវបានអនុញ្ញាតដោយផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

- មុខតំណែងទំនេរ
- ការបំពេញគ្រប់គ្រាន់នូវគុណវុឌ្ឍិនៃមុខតំណែងនិងលក្ខខណ្ឌនានាដែលតម្រូវដោយក្របខ័ណ្ឌនៃអង្គគ្រូបង្រៀនដែលត្រូវផ្លាស់ប្តូរចូល
- ការឯកភាពពីរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- ការឯកភាពពីរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
- ការពិនិត្យនិងសម្រេចពីប្រមុខរាជរដ្ឋាភិបាល។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៣៥ .-**

មន្ត្រីរាជការនៃអង្គគ្រូបង្រៀនដែលស្ថិតក្នុងថ្នាក់និងឋានន្តរសក្តិខ្ពស់បំផុត «ក.១.១» ហើយមិនទាន់ដល់អាយុចូលនិវត្តន៍ ត្រូវទទួលបានអត្ថប្រយោជន៍បន្ថែមផ្អែកលើអតីតភាពការងារ ដែលត្រូវកំណត់ដោយរាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៦
## ការផ្ទេរអង្គគ្រូបង្រៀន

**មាត្រា៣៦ .-**

ការផ្ទេរមន្ត្រីរាជការនៃអង្គគ្រូបង្រៀនទៅអង្គវិជ្ជាជីវៈផ្សេងទៀត អាចត្រូវបានអនុញ្ញាតដោយផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

- មុខតំណែងទំនេរ
- ការបំពេញគ្រប់គ្រាន់នូវគុណវុឌ្ឍិនៃមុខតំណែងនិងលក្ខខណ្ឌនានាដែលតម្រូវដោយអង្គវិជ្ជាជីវៈដែលត្រូវផ្ទេរចូល
- ការឯកភាពពីរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- ការឯកភាពពីប្រធានស្ថាប័នទទួលបន្ទុកអង្គវិជ្ជាជីវៈ
- ការឯកភាពពីប្រធានស្ថាប័នដែលត្រូវផ្ទេរចូល
- ការឯកភាពពីរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
- ការពិនិត្យនិងសម្រេចពីប្រមុខរាជរដ្ឋាភិបាល។

**មាត្រា៣៧ .-**

ការផ្ទេរមន្ត្រីរាជការនៃអង្គវិជ្ជាជីវៈផ្សេង មកក្នុងអង្គគ្រូបង្រៀន អាចត្រូវបានអនុញ្ញាតដោយផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

- មុខតំណែងទំនេរ
- ការបំពេញគ្រប់គ្រាន់នូវគុណវុឌ្ឍិនៃមុខតំណែងនិងលក្ខខណ្ឌនានាដែលតម្រូវដោយអង្គគ្រូបង្រៀន
- វិញ្ញាបនបត្រគរុសម្បទាវិជ្ជាជីវៈ សម្រាប់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន និងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតបឋម
- ការឯកភាពពីរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- ការឯកភាពពីប្រធានស្ថាប័នទទួលបន្ទុកអង្គវិជ្ជាជីវៈ
- ការឯកភាពពីប្រធានស្ថាប័នដែលត្រូវផ្ទេរចេញ
- ការឯកភាពពីរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
- ការពិនិត្យនិងសម្រេចពីប្រមុខរាជរដ្ឋាភិបាល។

## ផ្នែកទី៧
## ការដំឡើងឋានន្តរសក្តិនិង/ឬថ្នាក់

**មាត្រា៣៨ .-**

មន្ត្រីរាជការនៃអង្គគ្រូបង្រៀនដែលមានសិទ្ធិទទួលការដំឡើងឋានន្តរសក្តិនិង/ឬថ្នាក់ ត្រូវបំពេញព្រឹត្តិបត្រពិន្ទុ សម្រាប់ដំឡើងថ្នាក់របស់ខ្លួននៅរៀងរាល់ខែមករា នៃឆ្នាំនីមួយៗ។

ការពិនិត្យនិងការវាយតម្លៃសម្រាប់ការដំឡើងឋានន្តរសក្តិនិង/ឬថ្នាក់ ជូនមន្ត្រីរាជការនៃអង្គគ្រូបង្រៀន ត្រូវធ្វើឡើងនៅរៀងរាល់ខែមិថុនា នៃឆ្នាំនីមួយៗ។

ការសម្រេចលើការដំឡើងឋានន្តរសក្តិនិង/ឬថ្នាក់ ជូនមន្ត្រីរាជការនៃអង្គគ្រូបង្រៀន ត្រូវធ្វើឡើងនៅថ្ងៃទី១៣ ខែមេសា នៃឆ្នាំបន្ទាប់។

ការប្រាក់បៀវត្សផ្អែកលើឋានន្តរសក្តិនិង/ឬថ្នាក់ថ្មីរបស់មន្ត្រីរាជការនៃអង្គគ្រូបង្រៀន ត្រូវអនុវត្តចាប់ពីថ្ងៃទី១៥ ខែមេសា តទៅ។

**មាត្រា៣៩ .-**

ការដំឡើងឋានន្តរសក្តិនិង/ឬថ្នាក់ ជូនមន្ត្រីរាជការនៃអង្គគ្រូបង្រៀននៅថ្នាក់ជាតិ ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឬរដ្ឋមន្ត្រីក្រសួងឬប្រធានស្ថាប័នគ្រប់គ្រងមន្ត្រីសាមី។

**មាត្រា៤០ .-**

ការពិនិត្យ ការវាយតម្លៃ និងការសម្រេចសម្រាប់ការដំឡើងឋានន្តរសក្តិនិង/ឬថ្នាក់ ជូនមន្ត្រីរាជការនៃអង្គគ្រូបង្រៀន ដែលជាបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តដោយអនុលោមតាមបែបបទនិងនីតិវិធីដែលមានកំណត់នៅក្នុងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

## អនុផ្នែកទី១

## ការដំឡើងឋានន្តរសក្តិនិង/ឬថ្នាក់ ដោយឆ្លងកាត់ការពិនិត្យនិងការវាយតម្លៃ

**មាត្រា៤១ .-**

ការដំឡើងឋានន្តរសក្តិនិង/ឬថ្នាក់ប្រចាំឆ្នាំ ផ្អែកលើអតីតភាពការងារសម្រាប់មន្ត្រីរាជការនៃអង្គគ្រូបង្រៀន ត្រូវអនុវត្តផ្អែកលើគោលការណ៍ដូចខាងក្រោម៖

ក- មន្ត្រីរាជការនៃអង្គគ្រូបង្រៀន ត្រូវបានដំឡើងថ្នាក់ប្រចាំឆ្នាំ១(មួយ)ថ្នាក់ ក្នុងករណី៖

- បានបំពេញការងារក្នុងរយៈពេលអប្បបរមា២(ពីរ)ឆ្នាំ គិតចាប់ពីថ្ងៃតាំងស៊ប់ឬថ្ងៃឡើងថ្នាក់ចុងក្រោយរហូតដល់ថ្ងៃទី១៣ ខែមេសានៃឆ្នាំនីមួយៗ។ អតីតភាពការងារមន្ត្រីរាជការនៃអង្គគ្រូបង្រៀនដែលធ្វើការនៅតំបន់ឆ្ងាយដាច់ស្រយាល តំបន់ប៉ះពាល់សុខភាពឬគ្រោះថ្នាក់ ត្រូវគិតបន្ថែមពាក់កណ្តាលនៃអតីតភាពនេះទៀត ក្នុងការចុះឈ្មោះលើតារាងរាយនាមសម្រាប់ស្នើសុំដំឡើងថ្នាក់
- មិនត្រូវបានទទួលរងទណ្ឌកម្មខាងវិន័យថ្នាក់ទី២ឬទណ្ឌកម្មវិន័យថ្នាក់ទី១ រួមមាន ការស្តីបន្ទោសដោយមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន ការផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យ ការលុបឈ្មោះចេញពីតារាងឡើងឋានន្តរសក្តិនិង/ឬថ្នាក់ ក្នុងរយៈពេលនៃអតីតភាពការងារ២(ពីរ)ឆ្នាំ។

ខ- មន្ត្រីរាជការនៃអង្គគ្រូបង្រៀន ដែលមិនត្រូវបានដំឡើងឋានន្តរសក្តិនិង/ឬថ្នាក់ ដែលមានកំណត់ក្នុងចំណុច ក នៃមាត្រា៤១ នៃព្រះរាជក្រឹត្យនេះ ត្រូវបានដំឡើងថ្នាក់ប្រចាំឆ្នាំ១(មួយ)ថ្នាក់ ក្នុងឆ្នាំទី៣ នៃអតីតភាពការងាររបស់ខ្លួន លើកលែងតែមន្ត្រីរាជការនោះ ត្រូវបានទទួលទណ្ឌកម្មខាងវិន័យថ្នាក់ទី២។

គ- ការដំឡើងឋានន្តរសក្តិនិង/ឬថ្នាក់ប្រចាំឆ្នាំ ធ្វើបានម្តងតែមួយថ្នាក់ប៉ុណ្ណោះ។

**មាត្រា៤២ .-**

មន្ត្រីរាជការនៃអង្គគ្រូបង្រៀន ដែលបានបំពេញការងារមានស្នាដៃល្អពិសេសក្នុងមុខតំណែងដើម្បីគាំទ្រដល់វិស័យអប់រំ ត្រូវបានដំឡើងថ្នាក់១(មួយ)ថ្នាក់ ដោយពុំគិតពីលក្ខខណ្ឌអតីតភាពឡើយ។ ប្រធានអង្គភាពនៃមន្ត្រីសាមី ត្រូវលើកសំណើបេក្ខភាពមន្ត្រីដែលមានស្នាដៃល្អពិសេស ជូនគណៈកម្មការចំណាត់ថ្នាក់របស់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិសាមី។

**មាត្រា៤៣ .-**

ការពិនិត្យនិងការវាយតម្លៃសម្រាប់ការដំឡើងឋានន្តរសក្តិនិង/ឬថ្នាក់ ជូនមន្ត្រីរាជការនៃអង្គគ្រូបង្រៀននៅថ្នាក់ជាតិ ដូចមានចែងក្នុងមាត្រា៤១និងមាត្រា៤២ នៃព្រះរាជក្រឹត្យនេះ ត្រូវធ្វើឡើងដោយគណៈកម្មការចំណាត់ថ្នាក់របស់ក្រសួង ស្ថាប័នសាមី ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងឬប្រធានស្ថាប័នឬតំណាង | ប្រធាន |
| - អគ្គលេខាធិការ ឬអគ្គនាយក ឬក៏មុខតំណែងប្រហាក់ប្រហែល | អនុប្រធាន |
| - អគ្គលេខាធិការរង ឬអគ្គនាយករង ឬក៏មុខតំណែងប្រហាក់ប្រហែល១(មួយ)រូប | សមាជិក |
| - ប្រធាននាយកដ្ឋានធនធានមនុស្ស | សមាជិក |
| - តំណាងក្របខ័ណ្ឌនីមួយៗ១(មួយ)រូប | សមាជិក។ |

គណៈកម្មការនេះមានភារកិច្ចពិនិត្យនិងវាយតម្លៃសម្រាប់ការដំឡើងឋានន្តរសក្តិនិង/ឬថ្នាក់ ចំពោះមន្ត្រីរាជការនៃអង្គគ្រូបង្រៀនរបស់ថ្នាក់ជាតិ និងត្រូវរៀបចំសំណើសម្រាប់ការដំឡើងឋានន្តរសក្តិនិង/ឬថ្នាក់របស់មន្ត្រីរាជការស៊ីវិល ជូនប្រធានស្ថាប័នដើម្បីពិនិត្យនិងសម្រេច។

## អនុផ្នែកទី២
## ការដំឡើងឋានន្តរសក្តិនិង/ឬថ្នាក់ ដោយមិនឆ្លងកាត់ការវាយតម្លៃ

**មាត្រា៤៤ .-**

មន្ត្រីរាជការនៃអង្គគ្រូបង្រៀន ត្រូវបានដំឡើងថ្នាក់១(មួយ)ថ្នាក់ ដោយមិនឆ្លងកាត់ការវាយតម្លៃពីគណៈកម្មការចំណាត់ថ្នាក់ ក្នុងករណីដូចខាងក្រោម៖

- បានទទួលការបណ្តុះបណ្តាលដោយជោគជ័យក្នុងវគ្គសុក្រឹតការឬក្រឹតការណាមួយ ដែលមានរយៈពេលយ៉ាងហោចចាប់ពី៩(ប្រាំបួន)ខែ ឡើងទៅ នៅគ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ
- បានទទួលការបណ្តុះបណ្តាលជំនាញសមស្រប តាមការតម្រូវនៃអង្គគ្រូបង្រៀនដែលមានរយៈពេលយ៉ាងតិច១(មួយ)ឆ្នាំ ដោយមានសញ្ញាបត្រឬវិញ្ញាបនបត្របញ្ជាក់ទទួលស្គាល់
- ត្រូវបានផ្លាស់ប្តូរកន្លែងការងារតាមគោលការណ៍ពង្រាយមន្ត្រីរាជការដែលកំណត់ដោយរាជរដ្ឋាភិបាល
- មានអតីតភាពការងារយ៉ាងតិច២(ពីរ)ឆ្នាំ សម្រាប់មន្ត្រីរាជការដែលត្រូវបានអនុញ្ញាត៖
    - ឱ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម ឬ
    - ឱ្យទៅបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេសឬនៅតាមអង្គការអន្តរជាតិ។

មន្ត្រីរាជការនៃអង្គគ្រូបង្រៀនដែលទទួលបានការដំឡើងថ្នាក់តាមការបណ្តុះបណ្តាលឬតាមគោលការណ៍ពង្រាយមន្ត្រីរាជការ មានសិទ្ធិទទួលបានការដំឡើងថ្នាក់ប្រចាំឆ្នាំផ្អែកលើវេនជ្រើសរើសឬអតីតភាពដូចមានចែងក្នុងមាត្រា៤១ នៃព្រះរាជក្រឹត្យនេះ។

**មាត្រា៤៥ .-**

ឋានន្តរសក្តិកិត្តិយស អាចត្រូវផ្តល់ជូនមន្ត្រីរាជការនៃអង្គគ្រូបង្រៀនដែលចូលនិវត្តន៍ ឬលាលែង ឬក៏ដែលបានដាក់ឱ្យឈប់ធ្វើការងារដោយបាត់បង់សមត្ថភាពការងារ។

ឋានន្តរសក្តិកិត្តិយសជាកិច្ចបច្ឆាមរណៈ អាចផ្តល់ជូនមន្ត្រីរាជការដែលបានទទួលមរណភាព។

ឋានន្តរសក្តិទាំងពីរប្រភេទនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឬរដ្ឋមន្ត្រីក្រសួងឬប្រធានស្ថាប័នគ្រប់គ្រងមន្ត្រីសាមី ឬក៏ដីការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ឋានន្តរសក្តិកិត្តិយសឬឋានន្តរសក្តិកិត្តិយសជាកិច្ចបច្ឆាមរណៈ មិនត្រូវទទួលបានអត្ថប្រយោជន៍ហិរញ្ញវត្ថុឡើយ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

## ផ្នែកទី៨
## ស្ថានភាពបំពេញការងារនិងស្ថានភាពរដ្ឋបាល

**មាត្រា៤៦ .-**

ការដាក់ឱ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម ការដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ការកំណត់ពេលវេលាបំពេញការងារ ការឈប់សម្រាកពីការងារ និងការអនុវត្តទណ្ឌកម្មខាងវិន័យ ព្រមទាំងការផ្លាស់ប្តូរផ្សេងទៀតនៃស្ថានភាពរដ្ឋបាលនិងគ្រួសាររបស់មន្ត្រីរាជការនៃអង្គគ្រូបង្រៀន ត្រូវអនុវត្តដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ផ្នែកទី៩
## ការអភិវឌ្ឍសមត្ថភាពនិងគន្លងអាជីពគ្រូបង្រៀន

**មាត្រា៤៧ .-**

បុគ្គលិកអប់រំនៃអង្គគ្រូបង្រៀនក្នុងមុខតំណែងវិជ្ជាជីវៈនិងមុខតំណែងគ្រប់គ្រងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃអង្គគ្រូបង្រៀន ត្រូវទទួលការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំតាមរយៈវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលា ឬក៏វគ្គសិក្សាពាក់ព័ន្ធនឹងមុខតំណែងរបស់ខ្លួន ដើម្បីធ្វើបច្ចុប្បន្នកម្មចំណេះដឹង បង្កើនសមត្ថភាពវិជ្ជាជីវៈ និងសមត្ថភាពគ្រប់គ្រង ផ្អែកលើតម្រូវការនៃមុខតំណែងនីមួយៗ។

រយៈពេលនិងចំនួនក្រេឌីតសម្រាប់ការអភិវឌ្ឍសមត្ថភាពមុខតំណែងវិជ្ជាជីវៈនិងមុខតំណែងគ្រប់គ្រងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃអង្គគ្រូបង្រៀន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៤៨ .-**

មុខតំណែងនៃអង្គគ្រូបង្រៀន ត្រូវរៀបចំតាមគន្លងអាជីពគ្រូបង្រៀនដែលជាប្រព័ន្ធលើកទឹកចិត្តគ្រូបង្រៀន អ្នកគ្រប់គ្រង និងអ្នកឯកទេស ដើម្បីអភិវឌ្ឍសមត្ថភាព រក្សាទុក និងទាក់ទាញអ្នកមានសមត្ថភាពចូលរួមកសាងធនធានមនុស្ស និងគាំទ្រសមិទ្ធកម្មក្នុងការងារអប់រំ។

ក្របខ័ណ្ឌគន្លងអាជីពគ្រូបង្រៀន ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី១០
## វិន័យនិងសីលធម៌

**មាត្រា៤៩ .-**

បុគ្គលិកអប់រំនៃអង្គគ្រូបង្រៀន ត្រូវគោរពនិងអនុវត្តនូវបទប្បញ្ញត្តិដែលពាក់ព័ន្ធដូចខាងក្រោម៖

- សិទ្ធិនិងកាតព្វកិច្ចដែលមានកំណត់ដោយច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- គុណសម្បត្តិនៃឥរិយាបថរបស់មន្ត្រីរាជការ
- ក្រមសីលធម៌ឬក្រមប្រតិបត្តិមន្ត្រីរាជការស៊ីវិល
- ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន
- វិន័យនិងបទបញ្ជាផ្ទៃក្នុងដែលកំណត់ដោយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពដែលគ្រប់គ្រងមន្ត្រីរាជការ។

ROYAUME DU CAMBODGE ★ LE MINISTRE DU PALAIS ROYAL

## ផ្នែកទី១១
## ការចូលនិវត្តន៍និងការបាត់បង់សម្បទាវិជ្ជាជីវៈ

**មាត្រា៥០.-**

មន្ត្រីរាជការនៃអង្គគ្រូបង្រៀនគ្រប់ប្រភេទក្របខ័ណ្ឌ ត្រូវដាក់ឱ្យចូលនិវត្តន៍នៅពេលដល់អាយុ៦០ (ហុកសិប)ឆ្នាំ នៅថ្ងៃទី១ នៃខែបន្ទាប់ ឬត្រូវដាក់ឱ្យចូលនិវត្តន៍មុនកាលកំណត់ ឬកំណត់ថាបាត់បង់សម្បទាវិជ្ជាជីវៈ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មន្ត្រីរាជការនៃអង្គគ្រូបង្រៀនគ្រប់ប្រភេទក្របខ័ណ្ឌដែលចូលនិវត្តន៍តាមកាលកំណត់ ឬចូលនិវត្តន៍មុនកាលកំណត់ ឬបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវទទួលបានអត្ថប្រយោជន៍ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៥១ .-**

ក្នុងត្រីមាសទី១ នៃឆ្នាំនីមួយៗ ក្រសួងមុខងារសាធារណៈ ត្រូវជូនដំណឹងដល់គ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិអំពីស្ថានភាពមន្ត្រីរាជការនៃអង្គគ្រូបង្រៀនដែលត្រូវចូលនិវត្តន៍នៅឆ្នាំបន្ទាប់។ ក្រសួងមុខងារសាធារណៈ ត្រូវរៀបចំការដាក់មន្ត្រីរាជការនៃអង្គគ្រូបង្រៀនឱ្យចូលនិវត្តន៍ឱ្យបានមុន៦(ប្រាំមួយ)ខែ មុនកាលបរិច្ឆេទនៃការចូលនិវត្តន៍របស់មន្ត្រីសាមី ដោយបំពេញបែបបទនិងនីតិវិធីផ្អែកលើកម្រិតមុខតំណែងដូចខាងក្រោម៖

- មន្ត្រីរាជការក្នុងមុខតំណែងគ្រប់គ្រងនៃអង្គគ្រូបង្រៀន ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ ត្រូវដាក់ឱ្យចូលនិវត្តន៍និងបញ្ចប់មុខតំណែងដោយព្រះរាជក្រឹត្យ
- មន្ត្រីរាជការក្នុងមុខតំណែងគ្រប់គ្រងនៃអង្គគ្រូបង្រៀន ដែលត្រូវបានតែងតាំងដោយអនុក្រឹត្យ ត្រូវដាក់ឱ្យចូលនិវត្តន៍និងបញ្ចប់មុខតំណែងដោយអនុក្រឹត្យ
- មន្ត្រីរាជការក្នុងមុខតំណែងគ្រប់គ្រងនៃអង្គគ្រូបង្រៀន ដែលត្រូវបានតែងតាំងដោយប្រកាស ត្រូវដាក់ឱ្យចូលនិវត្តន៍និងបញ្ចប់មុខតំណែងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
- មន្ត្រីរាជការក្នុងមុខតំណែងគ្រប់គ្រងនៃអង្គគ្រូបង្រៀន ដែលត្រូវបានតែងតាំងដោយដីការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវដាក់ឱ្យចូលនិវត្តន៍និងបញ្ចប់មុខតំណែងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
- មន្ត្រីរាជការក្នុងមុខតំណែងវិជ្ជាជីវៈនៃអង្គគ្រូបង្រៀន ត្រូវដាក់ឱ្យចូលនិវត្តន៍និងបញ្ចប់មុខតំណែងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ។

មន្ត្រីរាជការនៃអង្គគ្រូបង្រៀន ត្រូវបានដាក់ឱ្យចូលនិវត្តន៍មុនកាលកំណត់និងបញ្ចប់មុខតំណែងដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ឬដីកា ផ្អែកលើកម្រិតនៃមុខតំណែងនីមួយៗ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មន្ត្រីរាជការនៃអង្គគ្រូបង្រៀន ត្រូវបានកំណត់ថាបាត់បង់សម្បទាវិជ្ជាជីវៈនិងបញ្ចប់មុខតំណែងដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ឬដីកា ផ្អែកលើកម្រិតនៃមុខតំណែងនីមួយៗ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៧
## អធិការអប់រំ

**មាត្រា៥២ .-**

អធិការអប់រំជាមន្ត្រីបច្ចេកទេសអធិការកិច្ច ដែលត្រូវបានជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការនៃអង្គគ្រូបង្រៀននិងទទួលការបណ្តុះបណ្តាលដើម្បីបំពេញការងារអធិការកិច្ចអប់រំ។

ការពិពណ៌នាមុខតំណែង គុណវុឌ្ឍិ និងប្រាក់បំណាច់មុខងារនៃអធិការអប់រំ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៥៣ .-**

ចំនួនមុខតំណែងអធិការអប់រំដែលត្រូវជ្រើសរើស ត្រូវកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា បន្ទាប់ពីមានការឯកភាពពីក្រសួងមុខងារសាធារណៈនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មន្ត្រីរាជការនៃអង្គគ្រូបង្រៀនដែលត្រូវបានជ្រើសរើស បណ្តុះបណ្តាល និងសម្រេចទទួលស្គាល់ជាអធិការអប់រំដោយក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានដំឡើងថ្នាក់ចំនួន១(មួយ)ថ្នាក់។

ក្រសួងអប់រំ យុវជន និងកីឡា គ្រប់គ្រងនិងបែងចែកភារកិច្ចដល់អធិការអប់រំ។

អធិការអប់រំត្រូវស្ថិតក្រោមបទប្បញ្ញត្តិទូទៅដែលអនុវត្តចំពោះបុគ្គលិកអប់រំនៃអង្គគ្រូបង្រៀន ដែលមានកំណត់ក្នុងព្រះរាជក្រឹត្យនេះ។

## ជំពូកទី៨
## បុគ្គលិកអប់រំក្រៅក្របខ័ណ្ឌមន្ត្រីរាជការ

**មាត្រា៥៤ .-**

បុគ្គលិកអប់រំក្រៅក្របខ័ណ្ឌមន្ត្រីរាជការ សំដៅដល់មន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ ឬមន្ត្រីផ្សេងទៀតដែលត្រូវបានជ្រើសរើសដើម្បីបំពេញមុខងារជាអ្នកបង្រៀនឬអ្នកស្រាវជ្រាវ នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ ឬអង្គភាពសាធារណៈផ្សេងទៀតរបស់រដ្ឋ។

បុគ្គលិកអប់រំក្រៅក្របខ័ណ្ឌមន្ត្រីរាជការ ត្រូវមានគុណវុឌ្ឍិពេញលេញសម្រាប់មុខតំណែងផ្នែកបង្រៀន ឬស្រាវជ្រាវ ដូចបុគ្គលិកអប់រំនៃអង្គគ្រូបង្រៀនជាមន្ត្រីរាជការ។

ការជ្រើសរើសនិងការគ្រប់គ្រងមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារឬមន្ត្រីផ្សេងទៀតដែលជាបុគ្គលិកអប់រំក្រៅក្របខ័ណ្ឌមន្ត្រីរាជការ ត្រូវស្ថិតក្រោមបទប្បញ្ញត្តិទូទៅដែលអនុវត្តចំពោះបុគ្គលិកអប់រំនៃអង្គគ្រូបង្រៀន ដែលមានកំណត់ក្នុងព្រះរាជក្រឹត្យនេះនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៩
## សមាហរណកម្មក្នុងក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់

**មាត្រា៥៥ .-**

មន្ត្រីរាជការស៊ីវិលដែលស្ថិតនៅក្រោមព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម ព្រះរាជក្រឹត្យលេខ

នស/រកត/០៧០១/២៤១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន ព្រះរាជក្រឹត្យលេខ នស/រកត/០៩០១/៣៤១ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតបឋម ត្រូវធ្វើសមាហរណកម្មទៅតាមក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់ ស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ ផ្អែកលើគោលការណ៍ដូចខាងក្រោម៖

- មន្ត្រីរាជការកំពុងបំពេញការងារផ្នែកបង្រៀន ឬស្រាវជ្រាវ ឬក៏គ្រប់គ្រង នៅតាមគ្រឹះស្ថានសិក្សា និងអង្គភាពសាធារណៈ ក្នុងវិស័យអប់រំនិងបណ្តុះបណ្តាល និង
- មានគុណវុឌ្ឍិនិងបំពេញលក្ខខណ្ឌគ្រប់គ្រាន់ដែលតម្រូវតាមប្រភេទក្របខ័ណ្ឌនៃអង្គគ្រូបង្រៀន ដែលកំណត់ដោយព្រះរាជក្រឹត្យនេះ។

ការធ្វើសមាហរណកម្មនេះ ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បន្ទាប់ពីទទួលបានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំ និងលើកផែនការដើម្បីធ្វើសមាហរណកម្មមន្ត្រីរាជការបច្ចុប្បន្ននៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន និងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតបឋម ទៅក្នុងក្របខ័ណ្ឌនៃអង្គគ្រូបង្រៀននៃព្រះរាជក្រឹត្យនេះ ជូនរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច។

**មាត្រា៥៦ .-**

មន្ត្រីរាជការក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន និងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតបឋម ដែលមិនត្រូវបានធ្វើសមាហរណកម្មទៅក្នុងលក្ខន្តិកៈនៃអង្គគ្រូបង្រៀនដែលកំណត់ដោយព្រះរាជក្រឹត្យនេះ ត្រូវបន្តស្ថិតក្រោមព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន ព្រះរាជក្រឹត្យលេខ នស/រកត/០៩០១/៣៤១ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតបឋម។

## ជំពូកទី១០

## អន្តរប្បញ្ញត្តិ

**មាត្រា៥៧ .-**

លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន ព្រះរាជក្រឹត្យលេខ នស/រកត/០៩០១/៣៤១ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតបឋម ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីជំនួស ស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី១១
## អវសានប្បញ្ញត្តិ

**មាត្រា៥៨ .-**

ព្រះរាជក្រឹត្យនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៧ តទៅ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥៩ .-**

សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ សៅរ៍ ១៤កើត ខែ ជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០២៦

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

នស. ២៦០៥. ៦០២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**